# ភាពចម្រូងចម្រាសនៃការបំបែកសំណុំរឿង ០០២

## ១) ប្រវត្តិនីតិវិធី

នៅថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចចេញដីកាបំបែកកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ទៅជាផ្នែកតូចៗ ដែលនឹងធ្វើឲ្យមានការជំនុំជម្រះជាច្រើនដំណាក់កាល ។[១] មានន័យថា អង្គជំនុំជម្រះសាលាដំបូងអាចជ្រើសរើសយកអង្គហេតុមួយចំនួនក្នុងចំណោមអង្គហេតុទាំងអស់ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង០០២ មកធ្វើការជំនុំជម្រះ និងសម្រេចសេចក្ដីតាមរយៈការចេញសាលក្រមមួយដំណាក់កាលម្ដងៗ ។ តាមរយៈដីកានេះ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចយកអង្គហេតុចំនួន៦ មកធ្វើការជំនុំជម្រះនៅក្នុងដំណាក់កាលទី១ ដែលជាទូទៅត្រូវបានហៅថា «សំណុំរឿង០០២/០១» ។ អង្គហេតុទាំងនោះរួមមាន៖ ទី១) រចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ទី២) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ នៅមុនពេលមានការបង្កើតរបបកម្ពុជាប្រជាធិបតេយ្យ និងនៅពេលជនជាប់ចោទម្នាក់ៗ បានទទួលការចាត់តាំងនូវតួនាទីទាំងនោះ ទី៣) តួនាទីរបស់ជនជាប់ចោទម្នាក់ៗ ក្នុងជួររដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ការទទួលខុសត្រូវរបស់ជនជាប់ចោទតាមការចាត់តាំង ក្របខ័ណ្ឌនៃសិទ្ធិអំណាចរបស់ជនជាប់ចោទ និងខ្សែបណ្ដាញទាក់ទងនៅក្នុងរយៈកាលដែលពាក់ព័ន្ធ និងយុត្តាធិការតាមពេលវេលារបស់តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ទី៤) គោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យស្ដីពីបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ទី៥) ការចោទប្រកាន់លើអង្គហេតុដែលបានរៀបរាប់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជននៅដំណាក់កាលទី១ និងដំណាក់កាលទី២ និងទី៦) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ(រួមមានៈ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញ(លើកលែងដោយហេតុផលសាសនា) ការជម្លៀសប្រជាជនដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ។[២] បន្ថែមលើនេះ នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបញ្ចូលបន្ថែមនូវអង្គហេតុថ្មីមួយទៀតដែលនឹងត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ នេះដែរគឺ

១-ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១ ហៅកាត់ថា «ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទី១»

២-ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទី១ កថាខណ្ឌទី៥ ។

ការសម្លាប់អតីតទាហាន និងមន្ត្រីរដ្ឋការនៃរបប លន់ នល់ នៅទួលពោធិ៍ជ្រៃ ។[៣] បន្ទាប់ពីអង្គហេតុទាំងនេះត្រូវបានជម្រះដោយចប់សព្វគ្រប់ នោះអង្គជំនុំជម្រះសាលាដំបូងនឹងចេញសាលក្រមមួយដោយសម្រេចផ្តន្ទាទោស ឬលើកលែងការចោទប្រកាន់ ចំពោះអង្គហេតុនៅក្នុងសំណុំរឿង០០២/០១នេះ ។ ចំណែកអង្គហេតុ និងបទចោទផ្សេងៗទៀត ដូចជា ការបំពារបំពានធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ បទប្រល័យពូជសាសន៍... ដែលនៅសល់ក្នុងដីកាដំណោះស្រាយ នឹងត្រូវយកមកជំនុំជម្រះក្នុងដំណាក់កាលក្រោយៗទៀត ។[៤] ទោះបីជាយ៉ាងណាក៏ដោយ អង្គជំនុំជម្រះសាលាដំបូង ពុំបានកំណត់ពេលជាក់លាក់ណាមួយដែលនឹងត្រូវលើកយកអង្គហេតុទាំងនេះមកធ្វើការជំនុំជម្រះឡើយ ពោលគឺអាស្រ័យទៅលើរយៈពេលនៃការបញ្ចប់សំណុំរឿង០០២/០១ ។

ក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធីនេះដែរ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់បន្ថែមថា ការសម្រេចកោះហៅ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ឲ្យមកផ្តល់សក្ខីកម្មនៅចំពោះមុខខ្លួន នឹងត្រូវពិចារណាអំពីភាពពាក់ព័ន្ធជាមួយអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ។ ផ្ទុយទៅវិញ សាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយណាដែលនឹងត្រូវផ្តល់សក្ខីកម្មដោយមិនជាប់ទាក់ទងនឹងអង្គហេតុណាមួយក្នុងចំណោមអង្គហេតុទាំង៧ដូចបានរៀបរាបខាងលើ នោះនឹងមិនត្រូវបានអង្គជំនុំជម្រះកោះហៅមកផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង០០២/០១ឡើយ ។ ជាងនេះទៅទៀត សំណើសុំមួយចំនួនរបស់ភាគីដែលមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុទាំងនេះ គឺមិនត្រូវបានអង្គជំនុំជម្រះយកពិចារណា និងសម្រេចនៅក្នុងអំឡុងពេលនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ឡើយ ។[៥]

---

៣-សូមមើលអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២, ឯកសារលេខ E163/5 អាចរកបានក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/22997

៤-ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទី១ កថាខណ្ឌទី៧ ។

៥-នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១១ ក្រុមមេធាវីការពារក្តី អៀង សារី បានស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង ចុះទៅពិនិត្យដល់ទីកន្លែងកើតហេតុ ដើម្បីអាចសង្កេតមើលភូមិសាស្ត្រ ស្ថានភាពនៃទីតាំង និងទំនាក់ទំនងជារូបវន្តរវាងទីតាំងនានា ដូចជា សហករណ៍ ការដ្ឋាន មន្ទីរសន្តិសុខ កន្លែងសម្លាប់មនុស្ស... ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ។ មានសំណើមួយចំនួនទៀតដូចជា «សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំសាលាដំបូងកំណត់បទល្មើសសារជាថ្មីទាក់ទងនឹងអង្គហេតុនៃការរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ» ។ សំណើទាំងនេះត្រូវបានអង្គជំនុំជម្រះពន្យារការសម្រេចរហូតដល់សំណុំរឿង០០២/១ ត្រូវបានជុំជម្រះចប់ ដោយអង្គជំនុំជម្រះផ្តល់ហេតុផលថា សំណើទាំងនេះមិនជាប់ពាក់ព័ន្ធនឹងអង្គហេតុដែលនឹងត្រូវជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ។

នៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០១២ សហព្រះរាជអាជ្ញាបានដាក់សំណើជូនអង្គជំនុំជម្រះសាលាដំបូងសុំឲ្យពង្រីកវិសាលភាពនៃសំណុំរឿង០០២/០១ ដោយបន្ថែមទីតាំងឧក្រិដ្ឋកម្មចំនួន ៣ ទៀតគឺ ទីតាំងសម្លាប់មនុស្សនៅស្រុក២១ ទីតាំងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ និង មន្ទីរសន្តិសុខស-២១(រួមទាំងទីតាំងសម្លាប់មនុស្សនៅជើងឯក) ។ សហព្រះរាជអាជ្ញាបានផ្តល់ហេតុផលថា ការបញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំង៣នេះទៅក្នុងសំណុំរឿង០០២/០១ គឺធ្វើឲ្យខ្លួនមានលទ្ធភាពក្នុងបង្ហាញភស្តុតាងអំពីធាតុចេតនានៃបទឧក្រិដ្ឋ និងគោលបំណងនៃការជម្លៀសប្រជាជនដោយបង្ខំចេញពីទីក្រុងភ្នំពេញ និងដើម្បីធានាថាវិសាលភាពនៃសំណុំរឿង០០២/០១ គឺមានភាពតំណាងសមស្របឲ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូល ហើយជនជាប់ចោទទាំងអស់នឹងត្រូវបានជំនុំជម្រះទោសអំពីឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលបានកើតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះបីជាយ៉ាងណាក្តី មានតែទីតាំងសម្លាប់មនុស្សនៅទួលពោធិ៍ជ្រៃតែមួយប៉ុណ្ណោះ ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងសម្រេចដាក់បញ្ចូលក្នុងសំណុំរឿង០០២/០១ ។ ចំណែកទីតាំងឧក្រិដ្ឋកម្មចំនួន ២ ទៀត គឺត្រូវបានបដិសេធចោល ។ អង្គជំនុំជម្រះបានផ្តល់សំអាងហេតុថា ការដាក់បញ្ចូលទីតាំងឧក្រិដ្ឋកម្មទាំងពីរនេះទៅក្នុងសំណុំរឿង០០២/០១ គឺនឹងធ្វើឲ្យមានការអូសបន្លាយពេលវេលាក្នុងការបញ្ចប់សំណុំរឿង០០២/០១ ដែលកត្តានេះនឹងនាំឲ្យកើតមានហានិភ័យក្នុងការមិនទទួលបានសាលក្រមណាមួយ ដោយសារជនជាប់ចោទមានវ័យចាស់ជរា និងមានសុខភាពមិនស្ថិតថេរ ។[៦]

ដោយឡែកក្រុមមេធាវីការពារក្តីជនជាប់ចោទ នួន ជា, អៀង សារី និង ខៀវ សំផន ដើមឡើយគឺគាំទ្រចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងការបំបែកសំណុំរឿង០០២ឲ្យទៅជាផ្នែកតូចៗ ។ ក្រោយមក បន្ទាប់ពីអង្គជំនុំជម្រះតុលាការកំពូលសម្រេចលុបចោលដីកាបំបែកសំណុំរឿងរបស់អង្គជំនុំជម្រះសាលាដំបូង(នឹងរៀបរាប់លម្អិតក្នុងចំណុចបន្ទាប់) ក្រុមមេធាវីការពារក្តីបានស្នើសុំមិនឲ្យមានការបំបែកសំណុំរឿងវិញ ។ ក្រុមមេធាវីការពារក្តីស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចធ្វើការជំនុំជម្រះលើសំណុំរឿង០០២ ទាំងមូល ដោយផ្តល់ហេតុផលថា ការជំនុំជម្រះនេះនឹងធ្វើឲ្យកូនក្តីរបស់ខ្លួនអាចការពារខ្លួនដោយរលូនៗ ជាងនេះទៅទៀត ទោះបីជាដាក់បញ្ចូលមន្ទីរសន្តិសុខស-២១

៦-«សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២ បន្ទាប់ពីមានសេចក្តីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូល ថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០១៣» ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៣ ឯកសារលេខ E284 ហៅកាត់ថា«សម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទី២» កថាខណ្ឌទី ២៥ និង ១៣៧

នៅក្នុងសំណុំរឿង០០២/០១ ក៏ពុំអាចតំណាងដីកាបញ្ជូនរឿងទៅជំនុំជម្រះទាំងមូលឲ្យបានសមស្រប ដែរ ។[៧]

ថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានចេញសេចក្តីសម្រេចធ្វើមោឃភាពលើដីកាបំបែកកិច្ចដំណើរនីតិវិធី(ចុះថ្ងៃទី ថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១១) សេចក្តីសម្រេចស្តីពីការពិចារណាឡើងវិញ(ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១) សេចក្តីសម្រេចដែលរងការជំទាស់(ចុះថ្ងៃទី៨ ខែតុលា ឆ្នាំ២០១២) និងអនុស្សរណៈទាំងអស់ ដែលចេញដោយអង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ ។[៨] អង្គជំនុំជម្រះតុលាការកំពូលបានលើកឡើងពីមូលហេតុសំខាន់ៗមួយចំនួន ដើម្បីយកធ្វើជាមូលដ្ឋានក្នុងការសម្រេចធ្វើមោឃភាពទៅលើសេចក្តីសម្រេចខាងលើនេះ ។ មូលហេតុទាំងនោះរួមមាន៖ ទី១) អង្គជំនុំជម្រះសាលាដំបូងខកខានពុំបានផ្តល់សំអាងហេតុឲ្យបានគ្រប់គ្រាន់ ដើម្បីបង្ហាញពី «អត្ថប្រយោជន៍នៃយុត្តិធម៌តម្រូវ» ដែលអង្គជំនុំជម្រះយកធ្វើជាមូលដ្ឋានក្នុងការបំបែកសំណុំរឿងឡើយ ហើយពុំបានស្តាប់យោបល់របស់ភាគីពាក់ព័ន្ធទៅនឹងលក្ខខណ្ឌទាំងនេះ ។[៩] ទី២) វិសាលភាពនៃអង្គហេតុដែលសាលាដំបូងសម្រេចយកមកជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ គឺពុំបានឆ្លុះបញ្ចាំង ឬតំណាងឲ្យដីកាបញ្ជូនរឿងជំនុំជម្រះទាំងមូលឲ្យបានសមស្របឡើយ ដែលកត្តានេះធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់សហព្រះរាជអាជ្ញា ហើយមិនអាចទទួលបានយុត្តិធម៌ដ៏មានអត្ថន័យពេញលេញនោះដែរ ។[១០] ទី៣) អង្គជំនុំជម្រះសាលាដំបូងពុំបានគ្រោង ឬរៀបចំពេលវេលាឲ្យបានច្បាស់លាស់ ដើម្បីធ្វើការជំនុំជម្រះលើអង្គហេតុដែលនៅសេសសល់ឡើយ ដែលកត្តាទាំងនេះអាចធ្វើឲ្យភាគីទាំងអស់មានការភាន់ច្រឡំ និង បានដឹកកប់យ៉ាងមានប្រសិទ្ធិភាពនូវបទចោទដែលនៅសល់ ។[១១]

ទោះបីជាយ៉ាងណាក្តី អង្គជំនុំជម្រះតុលាការកំពូលនៅតែទុកលទ្ធភាពឲ្យសាលាដំបូងធ្វើការពិចារណាអំពីលទ្ធភាពក្នុងបំបែកសំណុំរឿងដដែល ប្រសិនបើយល់ថាស្ថានភាពអត្ថប្រយោជន៍យុត្តិធម៌ត្រូវ

---

៧-សម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទី២ កថាខណ្ឌទី ៥២-៥៤

៨-សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីវិសាលភាពនៃសំណុំរឿងលេខ០០២/០១ ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ ។ ឯកសារលេខ E163/5/1/13 អាចរកបាន ក្នុងគេហទំព័រៈ http://www.eccc.gov.kh/document/court/25645 ។

៩-ឯកសារលេខ E163/5/1/13 កថាខណ្ឌទី៤៤

១០-ឯកសារលេខ E163/5/1/13 កថាខណ្ឌ ៤២, ៤៣ និង ៤៤

១១-ឯកសារលេខ E163/5/1/13 កថាខណ្ឌ៤៧

បានតម្រូវ ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់អនុសាសន៍ថា ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងនៅតែបន្តពិចារណាលើអត្ថប្រយោជន៍យុត្តិធម៌ដែលតម្រូវឲ្យត្រូវតែបំបែកសំណុំរឿង ០០២ មែននោះជាដំបូងអង្គជំនុំជម្រះសាលាដំបូងត្រូវអញ្ជើញភាគីនានាដាក់សារណា ដើម្បីស្តាប់មតិយោបល់របស់ភាគីទាក់ទងនឹងលក្ខខណ្ឌនៃការបំបែកនីតិវិធីលើសំណុំរឿង០០២ ។ ម៉្យាងវិញទៀត អង្គជំនុំជម្រះសាលាដំបូងគប្បីរៀបចំផែនការច្បាស់លាស់ និងដាក់ស្តែងសម្រាប់ការជំនុំជម្រះលើបទចោទដែលនៅសេសសល់នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ។ អង្គជំនុំជម្រះតុលាការកំពូលបានផ្តល់ជាដំណោះស្រាយថា ក្នុងករណីមានការបន្តការបំបែកកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង០០២ អង្គជំនុំជម្រះវិសាមញ្ញ គប្បីបង្កើតឲ្យមានអង្គចៅក្រមជំនុំជម្រះមួយបន្ថែមទៀត ដើម្បីគាំទ្រដល់ការជំនុំជម្រះឲ្យបានទាន់ពេលវេលាលើផ្នែកដែលនៅសេសសល់នៃសំណុំរឿង០០២ ។ អង្គចៅក្រមជំនុំជម្រះទី ២ នេះ នឹងការពារបានចំពោះការព្រួយបារម្ភទាក់ទងនឹងភាពលំអៀង ដែលទំនងជាមានបណ្តាលមកពីចៅក្រមដែលចូលរួមកាត់សេចក្តីនៅក្នុងការជំនុំជម្រះទី១ ហើយបន្តទៅកាត់សេចក្តីនៅក្នុងការជំនុំជម្រះទី២ ។ អង្គជំនុំជម្រះសាលាដំបូងទី ២ នេះ អាចចាប់ផ្តើមកិច្ចដំណើរការនីតិវិធីរបស់ខ្លួនភ្លាមៗ នៅខណៈពេលដែលអង្គជំនុំជម្រះសាលាដំបូងទី១ កំពុងជាប់រវល់ជាមួយនឹងការព្រាងសាលក្រមក្នុងសំណុំរឿង០០២/០១ ដោយធានាថាភាគីមិនទុកពេលឲ្យទំនេរក្នុងអំឡុងពេលនោះ ។ គួរកត់សម្គាល់ថា តាមបទពិសោធន៍របស់អង្គជំនុំជម្រះក្នុងការរៀបចំ និងចេញសាលក្រមក្នុងសំណុំរឿង០០១ ដែលមានជនជាប់ចោទ កាំង ហ្គេកអ៊ាវ ហៅ ឌុច គឺអង្គជំនុំជម្រះសាលាដំបូងបានចំណាយរយៈពេល ៨ខែ គិតចាប់ពីថ្ងៃសវនាការសន្និដ្ឋានបញ្ចប់ការដេញដោលរហូតដល់ថ្ងៃប្រកាសសាលក្រម ។ ចំណែកឯអង្គជំនុំជម្រះតុលាការកំពូលបានចំណាយពេលជាង ១០ខែក្នុងការរៀបចំ និងចេញសាលដីកា ។ ទំនងជាមូលហេតុនេះហើយដែលនាំឲ្យអង្គជំនុំជម្រះតុលាការកំពូលផ្តល់អនុសាសន៍ឲ្យបង្កើតអង្គចៅក្រមជំនុំជម្រះថ្មីមួយផ្សេងទៀតនៅសាលាដំបូង ដើម្បីជំនុំជម្រះលើបទល្មើសដែលនៅសល់ទាំងនេះបន្ទាប់ពីបញ្ចប់សវនាការសួរដេញដោលលើសំណុំរឿង០០២/០១ ។

## ២) មូលហេតុនៃការបំបែកសំណុំរឿង00២

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ គឺដោយផ្អែកទៅលើវិធាន ៨៩ស្ទួន២ នៃវិធានផ្ទៃក្នុងដែលចែងថា “*នៅពេលប្រយោជន៍យុត្តិធម៌តម្រូវនៅដំណាក់ណាមួយ អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យបំបែកកិច្ចដំណើរការនីតិវិធីពាក់ព័ន្ធនឹងជនជាប់ចោទមួយរូប ឬច្រើនរូប និងផ្នែកដែលពាក់ព័ន្ធនឹងបទចោទខ្លះ ឬ ទាំងអស់ដែលមាននៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ*” ។[១២] វិធាននេះត្រូវបានអនុម័តក្នុងអំឡុងខែកុម្ភៈ ឆ្នាំ២០១១ បន្ទាប់ពីមានការព្រួយបារម្ភថាការជំនុំជម្រះលើសំណុំរឿង

១២-វិធាន ៨៩ស្ទួនពីរនៃវិធានផ្ទៃក្នុងរបស់តុលាកាកាត់ទោសមេដឹកនាំខ្មែរក្រហម(វិសោធនកម្មលើកទី៨)

០០២ ទាំងមូលនឹងមិនចប់ ព្រោះជនជាប់ចោទទាំង៤រូប មានវ័យចាស់ជរា អាចស្លាប់ ឬ ពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងប៉ាន់ស្មានថា ប្រសិនបើពុំមានការបំបែកកិច្ចដំណើរការនីតិវិធីទេ នោះការជំនុំជម្រះលើសំណុំរឿង០០២ទាំងមូល នឹងមិនប្រើពេលតិចជាង៦ទៅ១០ឆ្នាំឡើយ ។ នៅក្នុងបរិបទទាំងនេះហើយដែលនាំឲ្យអង្គជំនុំជម្រះសម្រេចបំបែកសំណុំរឿង០០២ ឲ្យទៅជាផ្នែកតូចៗ ។[១៣]

នៅក្នុងសេចក្តីសម្រេចបំបែកសំណុំរឿង០០២ លើកទី១របស់អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះអះអាងថា ការបំបែកកិច្ចដំណើរការនីតិវិធីនេះ គឺដើម្បីប្រយោជន៍នៃយុត្តិធម៌ ។[១៤] នៅពេលប្រើពាក្យ«ដើម្បីផលប្រយោជន៍យុត្តិធម៌» អង្គជំនុំជម្រះផ្តោតទាំងយុត្តិធម៌សម្រាប់ជនរងគ្រោះ (សិទ្ធិទទួលបានយុត្តិធម៌ប្រកបដោយអត្ថន័យ និងទាន់ពេលវេលា) និងយុត្តិធម៌សម្រាប់ជនជាប់ចោទ (សិទ្ធិទទួលបានការជំនុំជម្រះដោយឆាប់រហ័ស) ។[១៥] មូលហេតុសំខាន់មួយទៀតរបស់អង្គជំនុំជម្រះ គឺដើម្បីឆ្លើយតបទៅនឹងក្តីបារម្ភមួយដែលថា តើភាពចាស់ជរារបស់ជនជាប់ចោទទាំង៤រូប នឹងអាចមានសម្បទាគ្រប់គ្រាន់ទាំងផ្លូវកាយ និង ផ្លូវចិត្ត ដើម្បីចូលរួមក្នុងសវនាការមួយដែលមានទំហំធំ មានភាពស្មុកស្មាញ និងត្រូវប្រើពេលវេលាយូរក្នុងការជំនុំជម្រះដែរឬយ៉ាងណា ។[១៦] គួរបញ្ជាក់ថា នៅខណៈពេលអង្គជំនុំជម្រះសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ អង្គជំនុំជម្រះក៏បានពិចារណាដល់លទ្ធភាពក្នុងការបំបែកជនជាប់ចោទមួយចំនួនចេញពីសំណុំរឿង០០២ ។ ការណ៍ធ្វើបែបនេះគឺដើម្បីទប់ស្កាត់មិនឲ្យមានការរំខានដល់កិច្ចដំណើរការនីតិវិធីដែលអាចឈានដល់ការផ្អាកសវនាការទាំងមូល ក្នុងករណីជនជាប់ចោទណាម្នាក់មានបញ្ហាសុខភាពមិនអាចចូលរួមសវនាការបាន ។ រហូតដល់ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចដោះលែង និងបំបែកជនជាប់ចោទ អៀង ធីរិទ្ធ ចេញពីសំណុំរឿង០០២ ដោយអង្គជំនុំជម្រះរកឃើញថា ជនជាប់ចោទរូបនេះពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ហើយបច្ចុប្បន្នត្រូវបានដោះលែងឲ្យមានសេរីភាព ដោយគ្រាន់តែភ្ជាប់នូវលក្ខខណ្ឌមួយចំនួនតែប៉ុណ្ណោះ ។

---

១៣- សេចក្តីសម្រេចបំបែកសំណុំរឿងលើកទី២ ត្រង់កថាខណ្ឌទី ៨៦ ។

១៤- ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទី១ កថាខណ្ឌទី៥ ។

១៥- ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើកទី១ កថាខណ្ឌទី៨ ។

១៦- «សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង និងសំណើសុំពាក់ព័ន្ធនានាព្រមទាំងឧបសម្ព័ន្ធ» ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១១ ឯកសារលេខ E124/7 កថាខណ្ឌទី១១នៃ ។

ក្រៅពីមូលហេតុដូចបានរៀបរាប់ខាងលើនេះ ការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូងគឺក្នុងគោលបំណង៖

- ដើម្បីបែងចែកសំណុំរឿង ០០២ ទៅជាផ្នែកៗដែលអាចគ្រប់គ្រងបាន ដែលផ្នែកនីមួយៗត្រូវការពេលខ្លីក្នុងការសម្រេច ។
- ដើម្បីធានាថា ការជំនុំជម្រះដំណាក់កាលដំបូងបានរួមបញ្ចូលនូវការពិនិត្យយ៉ាងហ្មត់ចត់លើបញ្ហាជាមូលដ្ឋាន និងការចោទប្រកាន់នានាប្រឆាំងនឹងជនជាប់ចោទទាំងអស់ ។
- ដើម្បីផ្តល់នូវមូលដ្ឋានសម្រាប់ការពិនិត្យលម្អិតលើបទចោទ និងការចោទប្រកាន់នានាដែលនៅសេសសល់ប្រឆាំងនឹងជនចាប់ចោទនៅក្នុងកាជំនុំជម្រះលើកក្រោយ ។
- ដើម្បីប្រតិបត្តិតាមលំដាប់នៃព្រឹត្តិការណ៍ និង/ឬលំដាប់លំដោយនៃដីកាដំណោះស្រាយតាមដែលអាចធ្វើទៅបាន(រវាងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៦) ។
- ដើម្បីធានាតាមដែលអាចធ្វើបានថា បញ្ហានានា ដែលត្រូវបានពិនិត្យនៅក្នុងការជំនុំជម្រះដំណាក់កាលដំបូង ផ្តល់នូវមូលដ្ឋានមួយសម្រាប់ការពិចារណាអំពីទម្រង់នៃការទទួលខុសត្រូវសហឧក្រិដ្ឋកម្មរួម តាមរយៈការរួមបញ្ចូលជនជាប់ចោទទាំងអស់ ។
- ដើម្បីជ្រើសរើសការចោទប្រកាន់លើអង្គហេតុទាំងឡាយ ដែលប៉ះពាល់ដល់ជនរងគ្រោះជាច្រើនតាមដែលអាចធ្វើបាន ។[១៧]

នៅក្នុងសេចក្តីសម្រេចបំបែកសំណុំរឿងជាលើកទី ២ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៣ អង្គជំនុំជម្រះសាលាដំបូងពុំមានការផ្លាស់ប្តូរជំហររបស់ខ្លួនឡើយក្នុងការកំណត់យកបញ្ហាសុខភាពរបស់ជនជាប់ចោទគឺជាបញ្ហាចំបងក្នុងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធីលើសំណុំរឿង០០២ និង កំណត់អំពីវិសាលភាពនៃអង្គហេតុដែលជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ។ មានបញ្ហាចំនួន ៥ ត្រូវបានអង្គជំនុំជម្រះសាលាដំបូងយកធ្វើជាមូលហេតុក្នុងការសម្រេចបំបែកសំណុំរឿង០០២ ។[១៨] បញ្ហាទាំងនោះរួមមាន ៖

ទី១) អាយុច្រើន និង ភាពទ្រុឌទ្រោមផ្នែកផ្លូវកាយរបស់ជនជាប់ចោទទាំងពីររូបដែលនៅសេសសល់ក្នុងសំណុំរឿង០០២ ៖ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ទោះបីជនជាប់ចោទ នួន ជា ត្រូវបានរកឃើញថាមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ប៉ុន្តែជនជាប់ចោទមានវ័យ ៨៦ ឆ្នាំ ថែមទាំងមានជំងឺប្រចាំកាយ(ជំងឺសរសៃបេះដូង ជំងឺសរសៃឈាមក្នុងខួរក្បាល...) ដែលកត្តាទាំងនេះធ្វើឲ្យខ្លួនមានការលំបាកនិងមានភាពមិនច្បាស់លាស់ក្នុងការប៉ាន់ស្មានអំពីស្ថានភាពសុខភាពរបស់ជនជាប់ចោទរូបនេះនៅពេល

---

១៧-ឯកសារលេខ E124/7 កថាខណ្ឌទី១០ ។

១៨-សេចក្តីសម្រេចបំបែកសំណុំរឿងលើកទី២ ត្រង់កថាខណ្ឌទី ១២៥ ។

ខាងមុខ ។ ដោយឡែកជនជាប់ចោទ ខៀវ សំផន អាយុ ៨២ ឆ្នាំ គឺធ្លាប់មានជំងឺដាច់សរសៃឈាមខួរក្បាល នៅចុងឆ្នាំ២០០៧ ហើយនៅពេលថ្មីៗនេះ (ក្នុងអំឡុងខែមករា ឆ្នាំ២០១៣) គឺត្រូវបានបញ្ជូនទៅមន្ទីរពេទ្យជាបន្ទាន់ ដោយសារមានជំងឺរលាកបំពង់កកម្រិតធ្ងន់ ។ ដូច្នេះកត្តាទាំងនេះហើយដែលតម្រូវឲ្យអង្គជំនុំជម្រះធ្វើយ៉ាងណាបញ្ចប់កិច្ចដំណើរការនីតិវិធីឲ្យបានលឿនបំផុត ។[១៩]

ទី២) ផលប្រយោជន៍សាធារណៈក្នុងការសម្រេចបានសាលក្រមឲ្យបានទាន់ពេលវេលាក្នុងសំណុំរឿង ០០២ ៖ នៅក្នុងចំណុចនេះអង្គជំនុំជម្រះសាលាដំបូងបានបង្ហាញអំពីក្តីបារម្ភមួយដែលថា ចុងក្រោយខ្លួននឹងពុំអាចសម្រេចបានសាលក្រមណាមួយសម្រាប់សំណុំរឿង០០២ ដោយសារតែជនជាប់ចោទបាត់បង់ជីវិត ឬពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញអំពីបទពិសោធន៍របស់ខ្លួនដែលបានបាត់បង់ឱកាសក្នុងការចេញសាលក្រមសម្រេចសេចក្តីសម្រាប់ជនជាប់ចោទ អៀង សារី ដែលខ្លួនបានចំណាយពេលជំនុំជម្រះជាងមួយឆ្នាំមកនេះ ដោយសារជនជាប់ចោទរូបនេះទទួលមរណៈភាព ។ ចំណែកជនជាប់ចោទ អៀង ធីរិទ្ធ គឺត្រូវបានដោះលែងឲ្យមានសេរីភាពព្រោះតែជនជាប់ចោទពុំមានសម្បទាគ្រប់គ្រាន់ក្នុងការចូលរួមសវនាការ ។ ដូច្នេះដំណើរការជំនុំជម្រះមួយដែលបានចំណាយពេលវេលា និង ធនធានយ៉ាងច្រើន ហើយចុងក្រោយពុំទទួលបានលទ្ធផលអ្វីទាំងអស់ នោះនឹងក្លាយជាការខកចិត្តយ៉ាងខ្លាំងសម្រាប់ជនរងគ្រោះនៃរបបខ្មែរក្រហម និងប្រទេសជាម្ចាស់ជំនួយទាំងអស់ ។[២០]

ទី៣) ផលប៉ះពាល់មិនច្បាស់លាស់អំពីរយៈពេលនៃកិច្ចដំណើរការនីតិវិធីប្រសិនបើមន្ទីរសន្តិសុខ ស-២១ ត្រូវបានដាក់បញ្ចូលទៅក្នុងសំណុំរឿង០០២/០១ ៖ អង្គជំនុំជម្រះយល់ឃើញថា ការបន្ថែមមន្ទីរសន្តិសុខស-២១ ទៅក្នុងសំណុំរឿង០០២/០១ អាចប្រឈមខ្លាំងនឹងការពន្យារពេលកិច្ចដំណើរការនីតិវិធីយ៉ាងយូរ ឬដោយគ្មានកំណត់ពេល ។ ទោះបីជាសហព្រះរាជអាជ្ញាផ្តល់ការប៉ាន់ស្មានថា សវនាការពាក់ព័ន្ធនឹងមន្ទីរស-២១ អាចនឹងត្រូវការពេលត្រឹមតែ ១៩ ថ្ងៃ ប៉ុន្តែអង្គជំនុំជម្រះយល់ឃើញថា យ៉ាងតិចក៏ត្រូវការពេល ២ ទៅ ៤ខែ ដើម្បីត្រឹមតែស្តាប់សក្ខីកម្មរបស់សាក្សីប៉ុណ្ណោះ ដោយពុំទាន់គិតដល់បញ្ហាផ្សេងៗដែលនឹងអាចកើតមាន ដូចជាបញ្ហាសុខភាពរបស់ជនជាប់ចោទ សាក្សី ដែលនាំឲ្យមានការផ្អាកសវនាការ ។ កត្តាទាំងនេះហើយដែលនាំឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចមិនដាក់បញ្ចូលមន្ទីរស-២១ ទៅក្នុងសំណុំរឿង០០២/០១ ។[២១]

១៩-សេចក្តីសម្រេចបំបែកសំណុំរឿងលើកទី២ ត្រង់កថាខណ្ឌទី ១២៦-១៣៤ ។
២០-សេចក្តីសម្រេចបំបែកសំណុំរឿងលើកទី២ ត្រង់កថាខណ្ឌទី ១៣៥-១៣៧ ។
២១-សេចក្តីសម្រេចបំបែកសំណុំរឿងលើកទី២ ត្រង់កថាខណ្ឌទី ១៣៨-១៤២ ។

ទី៤) ការពិចារណាលើការរៀបចំសវនាការ ៖ អង្គជំនុំជម្រះយល់ឃើញថា ការដាក់បញ្ចូលមន្ទីរសន្តិសុខស-២១បន្ថែម គឺជាបញ្ហាប្រឈមចំបងទាក់ទងនឹងការរៀបចំការជំនុំជម្រះក្តីនៅក្នុងសំណុំរឿង០០២/០១ ។ ពោលគឺនឹងនាំឲ្យមានការផ្លាស់ប្តូរកាលវិភាគរៀបចំសវនាការ និងពន្យារដល់ការចេញសាលក្រមលើសំណុំរឿង០០២/០១ ។[២២]

ទី៥) ភាពមិនច្បាស់លាស់ទាក់ទងនឹងរយៈពេលនៃការគាំទ្រខាងហិរញ្ញវត្ថុដល់អង្គជំនុំជម្រះវិសាមញ្ញ ៖ នេះគឺជាបញ្ហាថ្មីសន្ធាង ដែលត្រូវបានអង្គជំនុំជម្រះសាលាដំបូងលើកយកមកធ្វើជាមូលដ្ឋានក្នុងការសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ពោលគឺនៅក្នុងដីកាបំបែកសំណុំរឿងលើកទី១ បញ្ហានេះគឺពុំត្រូវបានលើកឡើងឡើយ ។ អង្គជំនុំជម្រះយល់ឃើញថា បញ្ហាកង្វះខាតថវិការគឺនៅតែជាបញ្ហាប្រឈមក្នុងការជំនុំជម្រះក្តីលើសំណុំរឿង ០០២ ឲ្យបានចប់សព្វគ្រប់ ។ អង្គជំនុំជម្រះបានលើកឡើងអំពីបទពិសោធន៍របស់ខ្លួនក្នុងការសម្រេចផ្អាកសវនាការ ដោយសារតែបុគ្គលិកផ្នែកបកប្រែភាសាធ្វើពហិការមិនចូលបម្រើការងារព្រោះតែគ្មានប្រាក់បៀវត្សន៍ជាច្រើនខែ ។ ជាងនេះទៅទៀត រហូតមកដល់ពេលនេះថវិការសម្រាប់ចំណាយក្នុងឆ្នាំ ២០១៣ និងដើមឆ្នាំ ២០១៤ គឺពុំទាន់ត្រូវបានធានានូវឡើយ ។ កត្តាទាំងនេះគឺជាផ្នែកមួយដែលតម្រូវឲ្យអង្គជំនុំជម្រះសាលាដំបូងសម្រេចបំបែកសំណុំរឿង ដើម្បីខ្លួនអាចមានលទ្ធភាពចេញសាលក្រម១ បន្ទាប់ពីការជំនុំជម្រះលើសំណុំរឿង ០០២/០១ ត្រូវបានបញ្ចប់ ។[២៣]

## ៣) ផលលំបាកក្នុងការអនុវត្តជាក់ស្តែងចំពោះការបំបែកសំណុំរឿង០០២

ដូចបានបញ្ជាក់រួចមកហើយអំពីអានុភាពនៃដីកាបំបែកសំណុំរឿងលើកទី១របស់អង្គជំនុំជម្រះសាលាដំបូងដែលកំណត់ថា ចំនួនដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ គឺនឹងត្រូវបានកាត់បន្ថយ ។ អង្គជំនុំជម្រះនឹងសម្រេចកោះហៅចំពោះតែ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ ដែលនឹងផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងអង្គហេតុដែលត្រូវយកមកជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ តែប៉ុណ្ណោះ ។ នេះគឺជាចំណុចចាប់ផ្តើមនៃបញ្ហាប្រឈមរបស់ភាគីទាំងអស់ រួមទាំងអង្គជំនុំជម្រះផងដែរ ក្នុងការកំណត់ និង សម្រេចជ្រើសរើស ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ ឲ្យមកផ្តល់សក្ខីកម្មនៅក្នុងសវនាការដំណាក់កាលទី១ ។ ក្នុងការស្នើសុំឲ្យកោះហៅ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី អ្នកជំនាញ ឬដាក់ឯកសារភស្តុតាងផ្សេងៗ ភាគីទាំងអស់គឺត្រូវបានតម្រូវឲ្យបង្ហាញអំពីភាពពាក់ព័ន្ធរវាងឯកសារភស្តុតាង ឬសក្ខីកម្មរបស់អ្នកទាំងនោះ ទៅនឹងអង្គហេតុដែលត្រូវជំនុំជម្រះក្នុងតំណាក់កាលទី១ ទើបអាចទទួល

២២- សេចក្តីសម្រេចបំបែកសំណុំរឿងលើកទី២ ត្រង់កថាខណ្ឌទី ១៤៣-១៤៤ ។

២៣- សេចក្តីសម្រេចបំបែកសំណុំរឿងលើកទី២ ត្រង់កថាខណ្ឌទី ១៤៥-១៤៦ ។

បាន ។ អង្គជំនុំជម្រះសាលាដំបូងធ្លាប់បានបើកសវនាការជាច្រើនដងស្តីអំពីការដាក់ឯកសារភស្តុតាងនៅចំពោះមុខខ្លួនដែលនឹងត្រូវយកមកដេញដោលដើម្បីសម្រេចសេចក្តីនៅក្នុងសំណុំរឿង០០២/០១ ។ សវនាការនេះអនុញ្ញាតឲ្យភាគីទាំងធ្វើការជំទាស់ចំពោះឯកសារទាំងឡាយណាដែលដាក់ដោយភាគីបដិបក្ខរបស់ខ្លួន ប្រសិនបើឯកសារទាំងនោះពុំមានភាពពាក់ព័ន្ធទៅនឹងអង្គហេតុដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង០០២/០១ ទោះបីឯកសារទាំងនោះត្រូវបានប្រើប្រាស់ដោយសហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាដំណោះស្រាយក៏ដោយ ។ គួរបញ្ជាក់ផងដែរថា កាលពីថ្ងៃទី ១១ ខែមករា ឆ្នាំ២០១៣ អង្គជំនុំជម្រះបានបើកសវនាការដាច់ដោយឡែកមួយ ដោយអនុញ្ញាតឲ្យភាគីទាំងអស់ បង្ហាញអំពីជំហររបស់ខ្លួនពាក់ព័ន្ធនឹងសំណើរបស់ក្រុមមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលសុំឲ្យអង្គជំនុំជម្រះកោះហៅកូនក្តីរបស់ខ្លួនមានរហស្សនាម TCCP-94 មកផ្តល់សក្ខីកម្មទាក់ទងនឹងតួនាទីរបស់ជនជាប់ចោទខៀវ សំផន និង អៀង សារី ។ ទោះបីជាសំណើនេះទទួលបានការគាំទ្រពីតំណាងសហព្រះរាជអាជ្ញា ប៉ុន្តែត្រូវបានជំទាស់ដោយក្រុមមេធាវីការពារក្តីជនជាប់ចោទទាំងបីក្រុម ។ ក្រុមមេធាវីការពារក្តីអះអាងថា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ គឺមិនបានស្ថិតនៅក្នុងព្រឹត្តិការណ៍ជម្លៀសប្រជាជនចេញពីក្រុងភ្នំពេញ ដែលអង្គជំនុំជម្រះកំពុងយកមកជំនុំជម្រះឡើយ ដូច្នេះអង្គជំនុំជម្រះពុំគប្បីកោះហៅមកផ្តល់សក្ខីកម្មឡើយ ។ បន្ទាប់ពីស្តាប់ការឆ្លើយតបគ្នាចុះឡើងៗរវាងភាគីទាំងអស់ អង្គជំនុំជម្រះជូនដំណឹងថាសេចក្តីសម្រេចរបស់ខ្លួននឹងចេញនៅពេលក្រោយ ។

បញ្ហាសំខាន់មួយទៀត ដែលអង្គជំនុំជម្រះសាលាដំបូងត្រូវប្រឈមមុខដោះស្រាយស្ទើរគ្រប់ពេលវេលានោះ គឺការជំទាស់របស់ភាគីដែលជាគូរបដិបក្ខ នៅពេលណាដែលមានភាគីណាមួយសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ ហួសពីវិសាលភាពនៃអង្គហេតុដែលត្រូវយកមកជំនុំជម្រះក្នុងសំណុំរឿង០០២/០១ ។នៅក្នុងសវនាការភាគីទាំងអស់ត្រូវបានកម្រិតឲ្យសួរដេញដោល ដើមបណ្តឹងរដ្ឋប្បវេណី សាក្សី និង អ្នកជំនាញ ត្រឹមអង្គហេតុដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០១ តែប៉ុណ្ណោះ ។ លើកលែងតែ សាក្សី និងអ្នកជំនាញមួយចំនួនប៉ុណ្ណោះ(ដូចជា ដេវីដ ឆេនដល័រ, ឡុង ណូរិន្ទ, ស្ហួង ស៊ីគឿន...) ដែលអង្គជំនុំជម្រះអនុញ្ញាតភាគីទាំងអស់សួរដេញដោលទៅលើអង្គហេតុទាំងមូលដែលបានកំណត់នៅក្នុងដីកាដំណោះស្រាយបញ្ជូនរឿងទៅជំនុំជម្រះ ។ ដូច្នេះនៅពេលមានភាគីណាមួយសួរហួសពីវិសាលភាពនៃអង្គហេតុដែលបានកំណត់ នោះនឹងទទួលរងការជំទាស់ពីភាគីម្ខាងទៀតជាមិនខាន ។ ឧទាហរណ៍ សវនាការសួរដេញដោលសាក្សី ឆោម សែ អតីតប្រធានមន្ទីរសន្តិសុខអ្នកខ្សែង ក្រុមតំណាងសហព្រះរាជអាជ្ញាបានចោទសួរពាក់ព័ន្ធនឹងការសម្លាប់អ្នកទោសនៅក្នុងមន្ទីរសន្តិសុខនេះ ប៉ុន្តែត្រូវបានក្រុមមេធាវីការពារក្តីជំទាស់ ដោយផ្តល់ហេតុផលថា មន្ទីរសន្តិសុខ

*អ្នកស្នៀង គឺមិនត្រូវបានដាក់បញ្ចូលនៅក្នុងសំណុំរឿង០០២/០១ នោះទេ ។ ដូច្នេះតំណាងសហព្រះរាជអាជ្ញាពុំអាចសួរស៊ីជម្រៅទៅដល់អង្គហេតុឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងមន្ទីរសន្តិសុខនេះឡើយ ។ តំណាងសហព្រះរាជអាជ្ញាឆ្លើយតបថា សំណួររបស់ខ្លួនគឺដើម្បីផ្ទុះបញ្ចាំងអំពីខ្សែសង្វាក់នៃការបញ្ជា និងរចនាសម្ព័ន្ធនៃការគ្រប់គ្រងនៅមន្ទីរសន្តិសុខអ្នកស្នៀង ។ អង្គជំនុំជម្រះបានសម្រេចបដិសេធចោលនូវសេចក្តីជំទាស់របស់ក្រុមមេធាវី ដោយទទួលយកអំណះអំណាងរបស់តំណាងសហព្រះរាជអាជ្ញា ហើយបង្គាប់ឲ្យសាក្សីឆ្លើយតបនឹងសំណួរ ។ មានឧទាហរណ៍ជាច្រើនដែលមានលក្ខណៈស្រដៀងៗគ្នានេះ ហើយមានពេលខ្លះអង្គជំនុំជម្រះពិតជាមានការលំបាកក្នុងការសម្រេចឲ្យបានត្រឹមត្រូវថា តើសំណួរដែលត្រូវបានជំទាស់ទាំងនោះ ស្ថិតនៅក្នុងវិសាលភាពនៃអង្គហេតុដែលខ្លួនកំពុងជំនុំជម្រះ ឬយ៉ាងណានោះទេ ។ នៅក្នុងសវនាការស្តាប់សក្ខីកម្មសាក្សី ហ៊ុន ឈុនលី ក្នុងអំឡុងខែធ្នូ ឆ្នាំ២០១២ អង្គជំនុំជម្រះធ្លាប់បានទទួលរងការរិះគន់ពីក្រុមមេធាវីការពារក្តី អៀង សារី ដែលថាអង្គជំនុំជម្រះកំពុងអនុវត្តបទដ្ឋានពីរផ្សេងៗក្នុងការសួរដេញដោលសាក្សីតែមួយ ដោយសារបញ្ហានៃការកំណត់វិសាលភាពនៃអង្គហេតុដែលត្រូវចោទសួរនេះ ។[២៤]*

ចប់

***ដោយៈ ចាន ប្រាថ្នា***

***ពិនិត្យ និងកែសម្រួលដោយ វ៉ាន់ថាន់ ពៅដារ៉ា***

---

*២៤-សូមមើលព្រឹត្តិបត្រ«សង្កេតការណ៍ដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហម» លេខ១៩ ចុះខែមករា ឆ្នាំ២០១២ ត្រង់ទំព័រទី ៤៤ ។ អាចរកបានក្នុងគេហទំព័រៈ* http://d.dccam.org/Projects/ECCC_Trial_Observation/pdf/Observation_19.pdf